# សាច់រឿង ផ្នែកទី ១

លូអ៊ីស បានត្រឡប់មកផ្ទះពីបេសកកម្មរបស់គាត់វិញជិតពីរឆ្នាំហើយ ។ ដោយសារគាត់បារម្ភពីការផ្គត់ផ្គង់ដល់គ្រួសារនាពេលអនាគត នោះគាត់បានសម្រេចចិត្តធ្វើការក្រៅម៉ោងបណ្ដើរ ចូលរៀនបណ្ដើរ ។ ពេលវេលារបស់គាត់មានកំណត់ ប៉ុន្តែគាត់រីករាយនឹងថ្នាក់វិទ្យាស្ថានប្រចាំសប្ដាហ៍របស់គាត់ ហើយដាក់វាជាអាទិភាព ។ ជាទូទៅ លូអ៊ីស បើកមើលប្រព័ន្ធផ្សព្វផ្សាយសង្គម និងលេងហ្គេមនៅលើឡានក្រុង ឬមុនពេលចូលរៀន ។ គាត់មិនបានណាត់ជួបនឹងនារីណាឡើយ តាំងពីគាត់មកដល់ផ្ទះវិញ ។ គាត់ប្រាប់គ្រួសាររបស់គាត់ថា គាត់មានអារម្មណ៍ថា វាល្អជាងដើម្បីរង់ចាំរហូតដល់គាត់រៀនចប់សិន ហើយចាំរៀបការពិតប្រាកដតែម្ដង ។ គាត់គិតថា ប្រសិនបើគាត់ត្រូវរៀបការក្នុងពេលឆាប់ៗ នោះវានឹងកើតឡើងដោយឯកឯង ។

អិមម៉ា ចូលរៀនថ្នាក់វិទ្យាស្ថានដូចគ្នានឹង លូអ៊ីស ដែរ ប៉ុន្តែមិនដែលបានជួបគាត់ទេ ។ ជាធម្មតា នាងអង្គុយជាមួយមិត្តរបស់នាង ហើយកម្រនឹងនិយាយជាមួយអ្នកផ្សេងទៀតណាស់ ។ ជាទូទៅ នាងមានអារម្មណ៍ធុញថប់ ពេលជួបនឹងបុរសៗ និងពេលដើរលេងជាគូ ។ នាងព្រួយចិត្តថា បើនាងចាប់ផ្ដើមទំនាក់ទំនងម្ដងទៀត នោះវានឹងបញ្ចប់ដូចជាទំនាក់ទំនងផ្សេងទៀតទាំងអស់ពីមុនរបស់នាងដែរ ។ នាងនឿយហត់ខាងសតិអារម្មណ៍ ហើយមានអារម្មណ៍ថា នាងមិនមានកម្លាំងគ្រប់គ្រាន់ដើម្បីនឹងចូលទៅក្នុងទំនាក់ទំនងមួយទៀតនោះទេ ។ នាងបានរៀនចប់កាលពីឆ្នាំមុន ហើយមានការងារពេញម៉ោងមួយ ។ នាងព្រួយបារម្ភថា នាងអាចនឹងមិនបានជួបស្នេហាដ៏ពិតប្រាកដមួយ ឬមិនបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធឡើយ ហើយគិតថា តើនាងគួរតែដើរលេងជាគូជាមួយនឹងអ្នកនៅក្រៅសាសនាចក្រដែរឬអត់ ។

ក្រោយពីបានអានសាច់រឿងរួមគ្នាហើយ សូមពិភាក្សាសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកគិតថា អ្វីទៅជាការព្រួយបារម្ភរបស់ លូអ៊ីស និង អិមម៉ា ?
- ដោយគិតពីអ្វីដែលយើងបានរៀននៅក្នុង ផ្នែកទី ១ នៃឯកសាររៀបចំ តើដំបូន្មានអ្វីខ្លះដែលអាចមានប្រយោជន៍ដល់ លូអ៊ីស ?
  តើដំបូន្មានអ្វីខ្លះដែលអាចមានប្រយោជន៍ដល់ អិមម៉ា ?
- ប្រសិនបើអ្នកមិនទាន់បានជជែកគ្នាអំពីវគ្គបទគម្ពីរដូចតទៅនេះនៅក្នុងការពិភាក្សាក្រុមរបស់អ្នកនៅឡើយទេ សូមអានវារួមគ្នា ហើយពិភាក្សាពីរបៀបដែលវាអាចទាក់ទងនឹង លូអ៊ីស និង អិមម៉ា ៖ សុភាសិត ៣:៥–៦; នីហ្វៃទី២ ២២:២; គោលលទ្ធិ និង សេចក្ដីសញ្ញា ៥៨:២៦–២៨ ។ តើអ្នកបានអនុវត្តសេចក្ដីជំនឿ ឬតើអ្នកអាចអនុវត្តសេចក្ដីជំនឿលើព្រះអម្ចាស់នៅក្នុងកិច្ចខិតខំរបស់អ្នក ដើម្បីស្វែងរកដៃគូដ៏អស់កល្បជានិច្ចតាមរបៀបណា ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved.